**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**អ្នកនាំពាក្យ គ.ជ.ប**
**លេខ:** ០៤៧ **គ.ជ.ប**

ថ្ងៃព្រហស្បតិ៍ ១០កើតខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែមិថុនា ឆ្នាំ២០២២

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលនៃកិច្ចប្រជុំរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

នាព្រឹកថ្ងៃព្រហស្បតិ៍ ទី៩ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ៩:០០ នៅសាលប្រជុំ គណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) មានបើកកិច្ចប្រជុំក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប្រាជ្ញ ចន្ទ** ប្រធាន គ.ជ.ប ដើម្បីពិនិត្យ និងសម្រេចលើបណ្តឹង/សំណុំរឿងចំនួនប្រាំបី ដែលប្តឹងតវ៉ា និងប្តឹងជំទាស់ទៅនឹងសេចក្តីសម្រេចរបស់គណៈកម្មការរៀបចំការបោះឆ្នោតរាជធានីភ្នំពេញ និងខេត្តត្បូងឃ្មុំ ពាក់ព័ន្ធទៅនឹងសកម្មភាពឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២។

ក្នុងសំណុំរឿងលេខ ១៥០ ១៥១ ១៥២ ១៥៣ ១៥៤ ១៥៧ និងលេខ ១៥៨ មានដើមបណ្តឹងជាប្រជាពលរដ្ឋ និងជាបេក្ខជនគណបក្សប្រជាជនកម្ពុជា ដែលបានប្តឹងជំទាស់ និងប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចរបស់គណៈកម្មការរៀបចំការបោះឆ្នោតរាជធានីភ្នំពេញ ដែលមិនបានផាកពិន័យជាប្រាក់ និងលុបឈ្មោះបេក្ខភាពឈរឈ្មោះរបស់គណបក្សភ្លើងទៀន នៅសង្កាត់កាកាបទី១ នៅសង្កាត់អូឡាំពិក នៅសង្កាត់វាលវង់ នៅសង្កាត់ក្រាំងធ្នង់ នៅសង្កាត់បាក់ខែង នៅសង្កាត់បឹងកេងកងទី៣ និងនៅសង្កាត់បឹងកេងកងទី២ ក្នុងរាជធានីភ្នំពេញ ដែលបានធ្វើសកម្មភាពឃោសនាដោយប្រើសារនយោបាយវាយប្រហារ លាបពណ៌ លើគូប្រជែង ញុះញង់ឱ្យមានការរើសអើង និងប្រមាថជាសាធារណៈចំពោះមេឃុំ ចៅសង្កាត់ របស់គណបក្សប្រជាជនកម្ពុជាដែលកំពុងដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍក្នុងមូលដ្ឋាននាពេលបច្ចុប្បន្ន។

ក្នុងសំណុំរឿងលេខ ១៥៦ ដើមបណ្តឹងឈ្មោះ **សុខ ស្រីនួន** ភេទស្រី កើតថ្ងៃទី២ ខែមីនា ឆ្នាំ១៩៨៧ មានទីលំនៅ ភូមិអ្នកតាទ្វារ ឃុំព្រះធាតុ ស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ ជាបេក្ខជនគណបក្សភ្លើងទៀន បានប្តឹងជំទាស់ទៅនឹងសេចក្តីសម្រេច ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២២ របស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តត្បូងឃ្មុំ ដែលសម្រេចផាកពិន័យរូបខ្លួន ចំនួន ៥.០០០.០០០ (ប្រាំលាន) រៀល។



អគារ គ.ជ.ប៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ៖ 012 959 666 / 092 105 556 / 012 855 018
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia អ៊ីម៉ែល៖ info@nec.gov.kh

បន្ទាប់ពីបានពិនិត្យសំណុំរឿងទាំងអស់ និងពិភាក្សាលើអង្គហេតុ និងអង្គច្បាប់រួចមក អង្គប្រជុំ គ.ជ.ប បានសម្រេចឆ្លើយតបជាលិខិតរដ្ឋបាលទៅដើមបណ្តឹងវិញលើសំណុំរឿងលេខ ១៥០ ១៥១ ១៥២ ១៥៣ ១៥៤ ១៥៧ និងលេខ ១៥៨ ដោយខ្លឹមសារលិខិតបានបញ្ជាក់ថា **សេចក្តីសម្រេចរបស់គណៈកម្មការរៀបចំការបោះឆ្នោតរាជធានីភ្នំពេញ ដែលបានសម្រេចឱ្យគណបក្សភ្លើងទៀនរាជធានីភ្នំពេញ បញ្ឈប់ជាបន្ទាន់នូវរាល់សកម្មភាពឃោសនាបោះឆ្នោត ដែលផ្ទុយពីច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត និងក្រមសីលធម៌របស់គណបក្សនយោបាយមានលក្ខណៈធូនល្មមទៅនឹងទង្វើប្រព្រឹត្តកំហុសរបស់គណបក្សភ្លើងទៀនរាជធានីភ្នំពេញហើយ។**

ដោយឡែកចំពោះសំណុំរឿងលេខ ១៥៦ គ.ជ.ប បានសម្រេចបដិសេធពាក្យបណ្តឹងរបស់ដើមបណ្តឹងឈ្មោះ **សុខ ស្រីនួន** ដោយតម្កល់សេចក្តីសម្រេចរបស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តត្បូងឃ្មុំ ដែលសម្រេចផាកពិន័យឈ្មោះ **សុខ ស្រីនួន** ចំនួន ៥.០០០.០០០ (ប្រាំលាន) រៀល ស្ថិតក្នុងកម្រិតអប្បបរិមា ស្របតាមមាត្រា ១៨១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ហើយ។

សេចក្តីសម្រេចរបស់ គ.ជ.ប ពាក់ព័ន្ធនឹងការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា៕



អគារ គ.ជ.ប៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ៖ 012 959 666 / 092 105 556 / 012 855 018
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia អ៊ីម៉ែល៖ info@nec.gov.kh